**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ២១២
ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៨
**<u>សាលដីកា</u>**
លេខៈ៨៥
ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ........... ជាប្រធាន
២-លោក .............. ជាចៅក្រម
៣-លោក .............. ជាចៅក្រមរបាយការណ៍
៤-លោក .................. ជាចៅក្រម
៥-លោក .............. ជាចៅក្រម
៦-លោក ............. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**
-អ្នកស្រី .................

**<u>តំណាងមហាអយ្យការ</u>**
-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ១៧៣ ចុះថ្ងៃទី៣០-០៤-៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៧៥ ចុះថ្ងៃទី០៣-១២-៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះសញតេទប្រុស អាយុ៤៤ ឆ្នាំជាតិខ្មែររបរកស៊ី រត់ម៉ូតូឌុប មានទីលំនៅក្រុម៣ ភូមិចំការសំរោងទី១ ឃុំចំការសំរោង ស្រុកស្វាយប៉ា ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ ញាណ ស៊ីម (រស) ម្តាយឈ្មោះ គីក លៀប (រស់)ប្រពន្ធឈ្មោះឡូញ យ៉ាន មានកូន០៦នាក់ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះសចណរតេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែររបរកស៊ី មុខរបរលក់ដូរ មានទីលំនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកស្វាយប៉ា ខេត្តបាត់ដំបង ។ឪពុកឈ្មោះ ហោ ប៊ុន (រ) ម្តាយឈ្មោះដួន គឹមសាត (រ) ប្តីឈ្មោះ ឃិត ប៊ុនរិទ្ធិមានកូន០៤នាក់ ។

**<u>កម្មវត្ថុបណ្តឹងៈ</u>** ប្តឹងសុំសិទ្ធិគ្រប់គ្រងដីលំនៅដ្ឋាន

-បានឃើញបណ្តឹងសាទុក្ខលេខ១០១ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៨ របស់ លោកសញបាន ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេច នៃសាលដីកាលេខ១៧៣ថ្ងៃទី៣០ ខែមេសាឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២១២ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១២-១១-៩៥ អ្នកស្រីសចណារប្ដឹងសុំឱ្យលោកសញដកដំណាំចេញពីដីរបស់ខ្លួន និងឱ្យចេញសងថ្លៃដំណាំខ្លួន និងសុំសិទ្ធិគ្រប់គ្រងដីនោះជាកម្មសិទ្ធិ ដោយសំអាង ហេតុថាខ្លួនបានរស់នៅភូមិចំការសំរោង១ តាំងពីឆ្នាំ១៩៧៩ ដោយបានកាប់ឆ្ការគ្រប់គ្រងមានទំហំ២១,៣មx២៣ម។ ក្នុងការគ្រប់គ្រងខ្លួនបានធ្វើផ្ទះទំហំ១០មx១១ម និងដំឡូងមីជារបង ចេក សាគូ ល្ហុង ប្រទាល ដើមថ្នាំ ។ លុះដល់ឆ្នាំ១៩៩២ លោកសញបានយកដំណាំមកដាំចូលលើដីរបស់ខ្លួនប្រវែង៦មx២១,៣ម ដោយបានកាប់ដំណាំខ្លួនអស់ម្ដងហើយ ពេលនោះខ្លួនបានទៅប្ដឹងរដ្ឋអំណាច ភូមិ ឃុំ ក៏បានចុះធ្វើអន្តរាគមន៍ដោយយក បង្គោលមកបោះជាព្រំប្រទល់ដើម្បីជៀសវាងទំនាស់ លុះដល់ថ្ងៃទី ០៩-០៧-៩៥ ស្រាប់តែ លោកសញបានមកតាប់បំផ្លាញដំណាំខ្លួនម្ដងទៀត ហើយយកចេកមកដាំលើដីរបស់ខ្លួន ទោះជារដ្ឋអំណាចមកហាមឃាត់ក៏មិនព្រមស្ដាប់ ។

បានឃើញសាលក្រមលេខ១៩៤ ចុះថ្ងៃទី១៩-០៧-៩៦ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

I-ក/ ទទួលពាក្យបណ្ដឹងចុះថ្ងៃទី១២-១១-៩៥ របស់ដើមចោទឈ្មោះសចណារប្ដឹងសុំគ្រប់គ្រងកាន់កាប់ដីទំនាស់ជាកម្មសិទ្ធិ និងប្ដឹងសុំឱ្យចុងចម្លើយឈ្មោះសញដកដំណាំចេញពីដីទំនាស់ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

ខ/ ទទួលសំណូមពររបស់ដើមចោទឈ្មោះសចណារប្ដឹងសុំទាមទារសំណងអន្តរាយ លើផលដំណាំថ្មី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

គ/ ទទួលសំណូមពររបស់ចុងចម្លើយឈ្មោះសញប្ដឹងសុំគ្រប់គ្រងកាន់កាប់ដីទំនាស់ជា កម្មសិទ្ធិទុកជាត្រឹមត្រូវតាមច្បាប់ និងទទួលសំណូមពររបស់ចុងចម្លើយប្ដឹងសុំប្រគល់ដីទំនាស់មួយបាតផ្ទះឱ្យដើមចោទឈ្មោះសចណារគ្រប់គ្រងជាកម្មសិទ្ធិទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនិងគតិច្បាប់ ។

II- បែងចែកដីទំនាស់ស្ថិតនៅ ភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកស្វាយប៉ោ ខេត្តបាត់ដំបងជា២ភាគ និងប្រគល់ឱ្យដើមចោទឈ្មោះសចណារនិងចុងចម្លើយឈ្មោះ សញគ្រប់គ្រងជាកម្មសិទ្ធិស្របច្បាប់ គិតចាប់ពីថ្ងៃដែលប្រកាសសាលក្រមនេះចូលជាស្ថាពរ ដោយគិតទំហំយកជាមូលដ្ឋាន តាមប្លង់បង្ហាញទីតាំងដីទំនាស់បណ្ដោះអាសន្ន ចុះថ្ងៃទី១០-០៤-៩៦ របស់ចៅក្រមផ្សះផ្សារ ស៊ើបអង្កេតគឺ:

ក. ដើមចោទឈ្មោះសចណារផ្ដល់ឲ្យភាគដីទំនាស់ប៉ែកខាងជើងក្នុងទំហំABFEA( Fជាចំណុចបង្កើតថ្មីលើជ្រុង BC,E ជាចំណុចបង្កើតថ្មីលើជ្រុង DA ) មានប្រវែងជ្រុងនីមួយៗគឺ :

- ជ្រុងAB = 12,70m

- ជ្រុង BF = 17,40m

- ជ្រុង FE = 15,50m

- ជ្រុង EA = 19,20m

ខ- ចុងចម្លើយឈ្មោះសញផ្តល់ឱ្យនូវភាគដីទំនាស់ប៉ែកខាងត្បូងក្នុងទំហំ FCDEF (F ជាចំណុចបង្កើតថ្មីលើជ្រុង BC, E ជាចំណុចបង្កើតថ្មីលើជ្រុង DA) មានប្រវែងជ្រុងនីមួយៗគឺ:

- ជ្រុង FC = 4,50m

- ជ្រុង CD = 16,50m

-ជ្រុង DE = 4,50m

–ជ្រុង EF = 15,50m

III...ឱ្យដើមចោទឈ្មោះសចណរនិងចុងចម្លើយឈ្មោះសញតាស់ដំណាំចេញរៀងៗខ្លួន ចេញពីដីដែលបានបែងចែកផ្តល់ឱ្យកម្មសិទ្ធិចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

IV...ឱ្យចុងចម្លើយឈ្មោះសញបង់ប្រាក់ប្រដាប់ក្តីគឺ :

-ពន្ធចុះបញ្ជី និងពន្ធហ្នឹង ចំនួន ១៨០០៛₀₀ᵢ₀₀

-រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛

-រង្វាន់ប្រគល់ដីកាកោះចំនួន ២០០០៛

-ចំណាយកិច្ចស៊ើបសួរចំនួន ៣០០០៛

ប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់រួចហើយ កាលបើហួសឧទ្ធរណ៍ឱ្យចុងចម្លើយសងប្រាក់ចំនួន៧.០០០៛ ទៅដើមចោទវិញ និងឱ្យចុងចម្លើយឈ្មោះសញបង់ពន្ធសមាមាត្រចំនួន ២.០០០៛ និងឱ្យដើមចោទបង់ពន្ធសមាមាត្រចំនួន១.០០០៛ ប្រាក់នេះកាត់៨០% បង់ចូលថវិការដ្ឋ ២០% ដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងព្រះរាជាណាចក្រកម្ពុជា ។

តាមអនុក្រឹត្យលេខ២៥អនក្រចុះថ្ងៃទី២២-០៨-៨៩ តាមសេចក្តីណែនាំអនុវត្តលេខ០៣ សណនចុះថ្ងៃទី០៣-០៦-៨៩ តាមមាត្រា ៣-១៩-២០-៦១-៦២-៦៣-៦៥-៦៨-៧១-៧៣-៧៤-៧៥ នៃច្បាប់ភូមិបាលដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ១០០ក្រ ចុះថ្ងៃទី១៣-១០-៩២ និងតាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៧ក្រ.ចុះថ្ងៃទី០៨-២-៩៣ ។

V-សាលក្រមនេះជំនុំជំរះប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវឧទ្ធរណ៍២ខែ គិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៩៩ ចុះថ្ងៃទី១៩-៨-៩៦ របស់លោកសញដែលប្តឹងជំទាស់នឹងសាលក្រមលេខ១៩៥ ចុះថ្ងៃទី១៩-០៧-៩៦ របស់តុលាការខេត្តបាត់ដំបងលើសេចក្តី សម្រេចទាំងមូល ។

បានឃើញសាលដីកាកំបាំងមុខរដ្ឋប្បវេណីលេខ១៧៣ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះសញចុះថ្ងៃទី១៩-៨-៩៦ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៩៥ ចុះថ្ងៃទី១៩-៧-៩៦ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដី១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធចុះបញ្ជី និងពន្ធហ៊ឹង២.៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៨៥០រៀល ចំណាយលើការប្រគល់ ដីកាកោះ ៥.០០០រៀល និងអាជ្ញាធរតុលាការ៥.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះសចណារនិង កំបាំងមុខឈ្មោះសញ។ បើកផ្លូវប្ដឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ១០១ ចុះថ្ងៃទី១២-៥-៩៨ របស់លោកសញបានប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ១៧៣ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសម្រេចទាំងមូល ។

បានស្ដាប់របាយការណ៍ របស់ទៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់ណាងមហាអយ្យការ

-បណ្ដឹងសាទុក្ខរបស់ចុងចម្លើយស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យ ពិចារណា ។

សាលដីការដ្ឋប្បវេណីលេខ១៧៣ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៨ របស់សាលា ឧទ្ធរណ៍ បានសម្រេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះសញជាចុងចម្លើយ និងជាម្ចាស់បណ្ដឹងសាទុក្ខនៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា ខ្លួនមិនសុខចិត្តថាតុលាការខេត្ត និងសាលាឧទ្ធរណ៍ មិនយុត្តិធម៌ ទេ ដូចនេះខ្លួនប្ដឹងមកតុលាការកំពូលនេះ សុំជួយរកយុត្តិធម៏ឱ្យខ្លួនផង ។

បានស្ដាប់ចម្លើយរបស់ឈ្មោះសៀក ចាន់ណារ៉ា ជាដើមចោទ និងជាចុងបណ្ដឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា ខ្លួនកាន់កាប់ដីនេះតាំងពីឆ្នាំ១៩៧៩ មកដល់ឆ្នាំ១៩៨៤ ឈ្មោះសញសំអាងថាដីតាំងពីដូនតាមក ពេលដែលខ្លួនធ្វើប្លង់ គាត់មិនតវ៉ាអ្វីទាំងអស់ ដល់ឆ្នាំ១៩៩២ ទើបគាត់មកទំនាស់ ។ ខ្លួនសុំសិទ្ធិគ្រប់គ្រងដីលំនៅដ្ឋានរបស់ខ្លួន ។

ក្រោយពីបានស្ដាប់របាយការណ៍ របស់ទៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសារបស់គូភាគី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១០១ ចុះថ្ងៃទី១២-០៥-៩៨ របស់លោកសញធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា ការកាន់កាប់ដីរបស់ដើមចោទ និងចុងចម្លើយមានភាពច្របូកច្របល់គ្នា ហើយការដែលតុលាការថ្នាក់ក្រោមធ្វើការបែងចែកឱ្យដាច់ ដោយឡែកពីគ្នានោះជាការត្រឹមត្រូវហើយ។

យល់ឃើញថាលោកសញម្ចាស់បណ្តឹងសាទុក្ខ បានទទួលដីកាបង្គាប់ឱ្យធ្វើ សារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែលោកពុំបានធ្វើសារណាជូនមកតុលាការ កំពូល តាមការកំណត់ទេ ហើយការលើកឡើងរបស់លោកនាពេលសវនាការនេះ ថាលោកសុំឱ្យវាស់តាម បង្កាន់ដៃសុំកាន់កាប់ដីនោះ តុលាការកំពូលពុំមានសមត្ថិកពិចារណាឡើយ ហើយម្យ៉ាងទៀតការប្រកាស កាន់កាប់ដីពុំអាចកំណត់ពីទំហំដីដែលខ្លួនបានកាន់កាប់ឡើយគឺ ប្រកាសជាឯកតោភាគី ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៧៣ ចុះថ្ងៃទី៣០-០៩-៩៨ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ១០១ ចុះថ្ងៃទី១២-០៥-៩៨ របស់លោកសញទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១៧៣ ចុះថ្ងៃទី៣០-០៩-៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០ រៀល ដែលលោកសញបានបង់រួចហើយគឺៈ

-ពន្ធចុះបញ្ជី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥០០០៛ សរុប១៩០០០៛ ។

បង្គាប់ឱ្យកូភាគីនៃរឿងក្តីនេះ បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តបាត់ដំបង។

៤.សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី១១-០៥-៩៩ ។